# លេខាធិការដ្ឋាន គ.ជ.អ.ប

# ការពិពណ៌នាការងារ (Job Description - JD)

| | |
|---|---|
| **កម្មវិធីជាតិ** | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (ផអ៣ទី២៖ ២០១៥-២០១៧) |
| **មុខតំណែង** | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក (DM Advisor) |
| **ទីកន្លែងបំពេញការងារ** | រដ្ឋបាលក្រុង ស្រុក |
| **រយៈពេល** | មួយឆ្នាំ (អាចបន្ត) |

## ១. សាវតារ

ផែនការអនុវត្តដំណាក់កាលទី១ (២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្តាលឲ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់ សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ ដែលនាំឲ្យរាជរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំលើកទី១០ របស់ គ.ជ.អ.ប កាលពីខែធ្នូ ឆ្នាំ២០១៤ បានសម្រេចបន្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២) ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧។

ចក្ខុវិស័យនៃផអ៣ទី២នេះគឺ "រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន"។ ផអ៣ទី២បន្ត ផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើរដ្ឋបាលក្រុង ស្រុក ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតផងដែរ។ ទាក់ទងជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ ក្នុងក្របខណ្ឌផអ៣ទី២ នឹងមិនអនុវត្តដោយអនុកម្មវិធីទៀតទេ។ ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ គឺជាក្រសួងស្ថាប័នទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយការងារកំណែទម្រង់ ជាពិសេសការផ្ទេរមុខងារនិងធនធានក្នុងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន។ សមិទ្ធផលសំខាន់ៗ នៃការផ្ទេរមុខងារគឺរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា ហើយការផ្តល់សេវានឹងត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសមស្រប និងនៅកៀកបំផុតនឹងប្រជាពលរដ្ឋ។ ការផ្ទេរមុខងារជាបឋមមានការផ្ទេរមុខងារជាក់លាក់និងសមស្របមួយចំនួនពីក្រសួងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមុខងារនៃសេវាទីប្រជុំជនពីរដ្ឋបាលខេត្ត ទៅរដ្ឋបាលក្រុងស្រុក។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត គឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រនៃការអភិវឌ្ឍ សមត្ថភាពដែលមានលក្ខណៈឆ្លើយតប និងប្រកបដោយការផ្តួចផ្តើម សំដៅសម្រេចបានដោយជោគជ័យក្នុងការ អភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការនឹងត្រូវបន្តពង្រឹងតាមរយៈទីប្រឹក្សានៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ជាលទ្ធផលនៃការអភិវឌ្ឍសមត្ថភាព គេសង្ឃឹមថាជំនួយបច្ចេកទេសនឹងត្រូវបានបន្ថយជាបណ្តើរៗ

ឬជំនួយបច្ចេកទេសទាំងនេះត្រូវបានបង្វែរពីថ្នាក់រាជធានី ខេត្ត ទៅថ្នាក់ក្រុង ស្រុក ជាពិសេសគឺត្រូវធ្វើការផ្លាស់ប្តូរនូវទម្លាប់និងឥរិយាបថនៃការប្រើប្រាស់ជំនួយបច្ចេកទេស ដែលទីប្រឹក្សាតែងតែបំពេញការងារជំនួសមន្ត្រីរាជការ ទៅជាបែបផែនដែលទីប្រឹក្សាត្រូវផ្តោតតែលើការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ។ ដូចនេះ បុគ្គលិកកិច្ចសន្យាទីប្រឹក្សាដែលស្ថិតនៅក្នុងក្របខណ្ឌជអ៣ទី២ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការសម្របសម្រួល និងការផ្តល់កិច្ចអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍សមត្ថភាពឱ្យបានច្រើនជាងមុន ប្រកបដោយគុណភាពនិងភាពសក្តិសិទ្ធជាជាងទម្លាប់នៃការធ្វើជំនួស។ បុគ្គលិកកិច្ចសន្យានិងទីប្រឹក្សាត្រូវផ្ទេរចំណេះដឹងដល់ដៃគូរបស់ខ្លួនយ៉ាងតិចក្នុង២ដំណាក់កាលៈ ដំណាក់កាលទី១ គឺជាការបង្រៀនផងនិងជួយធ្វើការផងដូចជា ជាបឋមត្រូវតម្រង់ទិសឲ្យយល់អំពីតួនាទីនិងភារកិច្ចរបស់ខ្លួន និងស្ថាប័នរបស់ខ្លួន របៀបបំពេញការងារ ការរៀបចំផែនការការងារ ការចាត់អាទិភាពការងារ ការនាំឲ្យចូលរួមផ្ទាល់ក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំតាមមូលដ្ឋានជាដើម។ ដំណាក់កាលទី២ គឺជាការពង្រឹងបន្ថែម និងការកែតម្រូវតាមរយៈការត្រួតពិនិត្យលើការបំពេញការងារ ដោយផ្អែកលើគុណភាព ភាពទាន់ពេល និងភាពមានទំនុកចិត្តក្នុងការបំពេញការងារ។ នេះជាលក្ខណៈវិនិច្ឆ័យចម្បងនៃការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកកិច្ចសន្យានិងទីប្រឹក្សាកម្មវិធី។

ដើម្បីជំនះបាននូវបញ្ហាប្រឈមគួរឲ្យព្រួយបារម្ភដែលអធិប្បាយខាងលើ ទីប្រឹក្សានិងបុគ្គលិកកិច្ចសន្យានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលក្នុងនោះរួមទាំងទីប្រឹក្សាគ្រប់គ្រងកម្មវិធីក្រុងស្រុក នឹងត្រូវជ្រើសរើស និងតែងតាំងឲ្យទៅបម្រើការងារយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សា គណៈអភិបាល និងការិយាល័យនានារបស់រដ្ឋបាលក្រុងស្រុក ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការបំពេញអណត្តិរបស់ខ្លួន។

លទ្ធផលនៃការបំពេញការងាររបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីក្រុងស្រុក នឹងត្រូវបានវិនិច្ឆ័យដោយផ្អែកលើលទ្ធផល និងកម្រិតនៃការផ្ទេរចំណេះដឹងនិងជំនាញរបស់បុគ្គលិកនោះទៅឱ្យមន្ត្រីរាជការ និងបុគ្គលិកដែលជាដៃគូរបស់ខ្លួន។

## ២. តួនាទី និងភារកិច្ច

### ២.១. តួនាទី និងភារកិច្ចទូទៅ

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីក្រុង ស្រុក នឹងផ្តល់ការប្រឹក្សាយោបល់ និងគាំទ្របច្ចេកទេសយ៉ាងសកម្មដល់រដ្ឋបាលក្រុង ស្រុក ដោយរាប់បញ្ចូលទាំងក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការកាតព្វកិច្ចនានារបស់ក្រុមប្រឹក្សា ដើម្បីអនុវត្តយុទ្ធសាស្ត្រនិងប្រព័ន្ធនានារបស់ជអ៣ទី២ ដែលមានដូចជា ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដំណើរការកសាងផែនការ អភិបាលកិច្ចនិងប្រជាធិបតេយ្យ ការអនុវត្តមុខងារដែលបានផ្ទេរ ការគ្រប់គ្រងមន្ត្រីរាជការ ការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ ការរៀបចំនិងគ្រប់គ្រងគម្រោង ការគាំទ្រមណ្ឌលធនធានមនុស្សរាជធានី ខេត្ត ការបញ្ជ្រាបយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងការពង្រឹងភាពជាម្ចាស់និងភាពជាដៃគូ។

### ២.២. ភារកិច្ចជាក់លាក់

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុកត្រូវអនុវត្តភារកិច្ចសំខាន់ៗនិងជាក់លាក់ដូចខាងក្រោមៈ

ក). **ផ្តល់សេវាប្រឹក្សាយោបល់ និងអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សាក្រុង ស្រុក** អំពីការពិគ្រោះពិភាក្សា ការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំគោលនយោបាយ ជំរុញការចូលរួម និងការត្រួតពិនិត្យមើលការអនុវត្ត តាមរយៈ ការហ្វឹកហ្វឺន និងប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីឲ្យមានការយល់ដឹងអំពីៈ

- ការពិភាក្សាពិគ្រោះយោបល់ មុនពេលឈានដល់ការធ្វើសេចក្តីសម្រេចលើកិច្ចការអ្វីមួយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- ការលើកកម្ពស់សំឡេងរបស់ស្ត្រី និងបុរសត្រូវបានពិចារណាស្មើគ្នានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា (ជាពិសេសនៅតាមកន្លែងការងារដែលស្ត្រីមានចំនួនតិចតួច)
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។
- មុខងាររបស់ក្រុមប្រឹក្សា ក្នុងការត្រួតពិនិត្យពីលើមើលរដ្ឋបាលក្រុង ស្រុក ដែលត្រូវអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។
- សារសំខាន់នៃការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មាន ជាមួយអង្គការសង្គមស៊ីវិលទាំងមុន និងក្រោយការរៀបចំគោលនយោបាយ ឬការធ្វើសេចក្តីសម្រេច

**ខ). ផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់**

- សម្របសម្រួលជាមួយការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ក្នុងការរៀបចំសិក្ខាសាលាប្រចាំត្រីមាសនៅថ្នាក់ក្រុង ស្រុក ដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួម ដែលសិក្ខាសាលា ទាំងនោះត្រូវផ្តោតសំខាន់លើគោលការណ៍សំខាន់ៗ នៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ការពិភាក្សាពិគ្រោះយោបល់របស់ក្រុមប្រឹក្សា ការធ្វើសេចក្តីសម្រេចចិត្ត សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល។ល។

**គ). ផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក**

- កសាងសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំការងារហិរញ្ញវត្ថុ ការងារលទ្ធកម្ម ការងារកសាងផែនការ ការងាររដ្ឋបាល និងការងារវិនិយោគ និងប្រព័ន្ធនីតិវិធី និងទម្រង់នានាទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ការទុកដាក់ឯកសារ និងការគ្រប់គ្រងបុគ្គលិក។
- ពង្រឹងសមត្ថភាព និងផ្តល់ការគាំទ្របច្ចេកទេសលើការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ស្របតាមច្បាប់រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច និងមុខងារដែលបានប្រគល់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៤២៧៤ និងឯកសារទាំងឡាយដែលទើបអនុម័តថ្មីៗ។
- ជួយគាំទ្រដល់ការសិក្សាតម្រូវការអភិវឌ្ឍសមត្ថភាព ការរៀបចំផែនការ និងការអនុវត្តអន្តរាគមន៍អភិវឌ្ឍសមត្ថភាពទៅតាមតម្រូវការចាំបាច់។
- ចូលរួមពិនិត្យឡើងវិញពីផែនការអន្តរាគមន៍អភិវឌ្ឍស្ថាប័ន ដោយប្រើប្រាស់លទ្ធផលពីការវាយតម្លៃស្ថាប័នដែលបានរចនាទៅតាមតម្រូវការជាក់លាក់នៅតាមក្រុង ស្រុកកន្លងមក។
- អភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក អំពីគោលការណ៍ណែនាំ និងនីតិវិធីនានាទាក់ទងនឹងការរៀបចំកម្មវិធីវិនិយោគ ការចុះកិច្ចសន្យា ការអនុវត្ត និងការត្រួតពិនិត្យ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលបណ្តើរអនុវត្តបណ្តើរ នៅអំឡុងពេលអនុវត្ត។
- ជួយផ្តល់យោបល់ដល់រដ្ឋបាលក្រុង ស្រុក លើការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ។
- ពង្រឹងការអនុវត្តតួនាទី របស់មន្ត្រីសេវាសង្គម ក្រុង ស្រុក ក្នុងការអភិវឌ្ឍសមត្ថភាព គ.ក.ស.ក និង គ.ក.ន.ក ។

**ឃ. មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត**

- ជួយសម្របសម្រួល និងឬអនុវត្តសកម្មភាពអភិវឌ្ឍន៍សមត្ថភាពទាំងអស់ដែលអនុវត្តនៅរដ្ឋបាលក្រុងស្រុកពាក់ព័ន្ធនឹងក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិក។
- ជួយធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រុងស្រុក និងឬធ្វើបច្ចុប្បន្នភាពផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័នរបស់រដ្ឋបាលក្រុងស្រុក

ផ្អែកតាមលទ្ធផលនៃការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាព។

- ជួយរៀបចំតាក់តែង និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន ដើម្បីអភិវឌ្ឍសមត្ថភាព ក្រុមប្រឹក្សាគណៈអភិបាល មន្ត្រីបុគ្គលិក ផ្អែកតាមផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន។
- ចូលរួមចំណែកក្នុងការវាយតម្លៃលទ្ធផលនៃការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលក្រុងស្រុក និងជួយរៀបចំបញ្ជីអ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាពដែលមានសក្តានុពល។
- ចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលក្រុងស្រុកទៅលើប្រធានបទជាក់លាក់មួយចំនួន ក្នុងតួនាទីជាគ្រូបណ្តុះបណ្តាល ឬជាអ្នកសម្របសម្រួលជាដើម។

**ង. ការសម្របសម្រួល**

- សម្របសម្រួល និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំផែនការសកម្មភាព និងថវិកា ផអ៣ ប្រចាំឆ្នាំ និងលើដំណើរការអនុវត្តការងារផអ៣។
- ពិគ្រោះយោបល់ជាប្រចាំជាមួយការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ដើម្បីធានាថាសកម្មភាពនានាដែលគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានគ្រោង និងគ្រប់គ្រងយ៉ាងត្រឹមត្រូវ។
- គាំទ្រដល់ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុឱ្យមានសមត្ថភាពក្នុងការរៀបចំថវិកា គណនេយ្យ ការទូទាត់ វិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មប្រកបដោយតម្លាភាព និងរៀបចំរបាយការណ៍ស្របតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រុង ស្រុក។
- ជួយសម្របសម្រួល និងគាំទ្របច្ចេកទេសក្នុងអំឡុងពេលដំណើរការកសាងផែនការ ដើម្បីធានាថាបានអនុវត្តតាមសេចក្តីណែនាំ និងដាក់ជូនក្រុមប្រឹក្សាអនុម័តទាន់ពេលវេលា។
- សម្របសម្រួលជាមួយនាយករដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងផ្ទៃក្នុង និងវេទិកាសាធារណៈ និងធានាថាលទ្ធផលត្រូវបានចងក្រង សម្រាប់ការតាមដាន។
- គាំទ្រ និងសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក ដើម្បីលើកកំពស់ភាពជាម្ចាស់ការងារទំនាក់ទំនងនិងបណ្តាញ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។

**ច. ការបញ្ជ្រាបយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី**

- ធានា និងចូលរួមចំណែកក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍសមត្ថភាព និងរៀបចំវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុងស្រុក។

**ឆ. ការងារផ្សេងៗទៀត**

- បំពេញភារកិច្ចផ្សេងៗទៀតដែលស្នើសុំដោយលេខាធិការដ្ឋាន គ.ជ.អ.ប ស្ថាប័នអនុវត្តគម្រោង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត។

## ៣. ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាព

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុកនៃផអ៣ទី២ ត្រូវចុះកិច្ចសន្យាបំពេញការងារជាមួយ និងស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

នៅថ្នាក់ខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់ពីអភិបាលខេត្ត តាមរយៈនាយករដ្ឋបាលខេត្ត និងស្ថិតនៅក្រោមការគ្រប់គ្រង និងសម្របសម្រួលបច្ចេកទេសរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត។ ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុកបំពេញការងារនៅតាមក្រុង ស្រុកដែលបានកំណត់ និងត្រូវមានគណនេយ្យភាព ព្រមទាំងរាយការណ៍អំពីការបំពេញភារកិច្ចរបស់ខ្លួនជូនក្រុមប្រឹក្សា និងគណៈអភិបាល តាមរយៈនាយករដ្ឋបាល ក្រុង ស្រុក ដោយចម្លងជូនរដ្ឋបាលខេត្ត តាមរយៈទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត។

## ៤. លក្ខណៈសម្បត្តិ

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- បញ្ចប់**បរិញ្ញាបត្រ** ឬសញ្ញាបត្រមានតម្លៃស្មើ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ កសិកម្ម បរិស្ថាន មុខងារសាធារណៈ ការគ្រប់គ្រង ទំនាក់ទំនង ធុរៈកិច្ច ច្បាប់ និងសេដ្ឋកិច្ចជាដើម។
- មានបទពិសោធន៍ការងារជាប់គ្នា**យ៉ាងតិច៣ឆ្នាំ** ទាក់ទងនឹងមុខតំណែងខាងលើ ជាពិសេសជាមួយការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- មានជំនាញ និងបទពិសោធន៍នៅក្នុងការអភិវឌ្ឍន៍សមត្ថភាពជាពិសេសការសម្របសម្រួល ការហ្វឹកហ្វឺន ការបង្វឹក និងបណ្តុះបណ្តាល ដោយរួមទាំងការសិក្សាអំពីតម្រូវការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលគ្រូឧទ្ទេស។
- មានចំណេះដឹងទាក់ទងនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ជាពិសេសតួនាទីនិងការទទួលខុសត្រូវរវាងក្រុមប្រឹក្សា និងគណៈអភិបាល) វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កម្មវិធីជាតិនិងផែនការអនុវត្តរយៈពេល០៣ឆ្នាំ និងឯកសារពាក់ព័ន្ធដែលទើបអនុម័តថ្មីៗ។
- មានការយល់ដឹងច្បាស់អំពីប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុ ជាពិសេស ការរៀបចំថវិកា និងវិធីសាស្រ្តលទ្ធកម្មទាំងថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។
- មានការយល់ដឹងលើការរៀបចំនិងគ្រប់គ្រងគម្រោងទាំងថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ ដោយផ្អែកលើPIM ក្រុងស្រុក និង PIM ឃុំ សង្កាត់។
- មានបទពិសោធន៍ក្នុងការសម្របសម្រួលការងារ និងទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា។
- មានចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ Ms Office, Internet, E-mail, Office Machine។
- មានសមត្ថភាពច្បាស់លាស់ក្នុងការសរសេរជាភាសាខ្មែរ និងមានចំណេះដឹងជាមូលដ្ឋានផ្នែកភាសាអង់គ្លេសកាន់តែប្រសើរ។

**<u>បញ្ជាក់</u>៖ មុខតំណែងនេះជាប្រភេទកិច្ចសន្យាការងារធ្វើការពេញម៉ោង។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល នោះបេក្ខជនត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ។**